

# ព័ត៌មានអំពីការវាយតម្លៃ

AEAS®

# ការវាយតម្លៃរបស់ AEAS ផ្តល់ការធ្វើតេស្តដ៏ទូលំទូលាយសម្រាប់សិស្សសាលាបឋមសិក្សា និងមធ្យមសិក្សាមកពីតំបន់ដែលមិននិយាយភាសាអង់គ្លេស ដែលប្រាថ្នាចង់សិក្សាភាសាអង់គ្លេសថ្នាក់មធ្យមក្នុងប្រទេសអូស្ត្រាលី និងប្រទេសដទៃទៀត។

សេវាវាយតម្លៃការអប់រំនៅប្រទេសអូស្ត្រាលី (AEAS) បានធ្វើតេស្តសិស្សបរទេស សម្រាប់ការចូលរៀនភាសាអង់គ្លេសថ្នាក់មធ្យមអស់រយៈពេលច្រើនជាង៣០ឆ្នាំ។ សេវាធ្វើតេស្តរបស់ AEAS ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយសាលាឯកជន និងសាលារដ្ឋនៅក្នុងប្រទេសអូស្ត្រាលី និងសាលាដទៃទៀតនៅជុំវិញពិភពលោក។

របាយការណ៍មួយរបស់ AEAS ជួយយ៉ាងសំខាន់ដល់ការដាក់ពាក្យសុំរបស់សិស្សម្នាក់ៗ ក្នុងការចុះឈ្មោះដោយផ្តល់ការវាយតម្លៃយ៉ាងច្បាស់ និងទូលំទូលាយពីសមត្ថភាពរបស់ពួកគេ។ ព័ត៌មានគឺសំខាន់ណាស់សម្រាប់បុគ្គលិកទទួលចុះឈ្មោះចូលរៀនសម្រាប់មាតាបិតា និងសម្រាប់ភ្នាក់ងារដទៃទៀត។ ការបញ្ជាក់ថាបានចុះឈ្មោះចូលរៀនក្នុងសាលាមួយដោយការប្រើប្រាស់របាយការណ៍របស់ AEAS ជាញឹកញាប់ គឺជាជំហានទីមួយរបស់សិស្សឆ្ពោះទៅកាន់ការបំពេញការអប់រំនៅសាលាមធ្យមសិក្សាមួយដែលមានគុណភាពខ្ពស់។ ពេលនោះពួកគេត្រូវបានដាក់ចូលទៅក្នុងជំរើសល្អក្នុងការចូលរៀននៅក្នុងសាកលវិទ្យាល័យដ៏ល្អៗនៅក្នុងប្រទេសអូស្ត្រាលី និងនៅជុំវិញពិភពលោក។ សាលារៀនទាំងឡាយដែលទទួលយកការវាយតម្លៃរបស់ AEAS មានចុះបញ្ជីនៅក្នុងគេហទំព័រ **www.aeas.com.au**។

## ទីបន្ទាល់

“ការធ្វើតេស្តរបស់ AEAS មិនដូចគ្នានឹងការធ្វើតេស្តដែលអ្នកធ្វើនៅសាលារៀននោះទេ។ វាមិនប្រាប់ពីការជាប់ ឬធ្លាក់នោះទេ។ វាគ្រាន់តែប្រាប់អ្នកពីជំនាញភាសាអង់គ្លេសរបស់អ្នកដែលត្រូវការបំប៉នបន្ថែមប៉ុណ្ណោះ។ របាយការណ៍ AEAS ប្រាប់ពីកំរិតល្អិតល្អន់នៃភាសាអង់គ្លេសដែលខ្ញុំត្រូវរៀន ហើយការរៀនមុខវិជ្ជានេះបានជួយឲ្យខ្ញុំចាប់ផ្តើមចូលរៀន ជាមួយនឹងជំនាញភាសាអង់គ្លេសដ៏ខ្លាំងក្លាមួយ។ ខ្ញុំបានបង្កើតមិត្តភក្តិជាច្រើនសម្បើមនៅឯសាលាថ្មី ហើយខ្ញុំក៏ពិតជាកំពុងទទួលបាននូវពិន្ទុល្អៗផងដែរ! ការធ្វើតេស្តរបស់ AEASគឺជាមធ្យោបាយដ៏ប្រសើរបំផុត ដើម្បីឲ្យយល់ដឹងពីការត្រៀមខ្លួនដើម្បីទៅរៀននៅបរទេស។

*Tom Nguyen មកពីប្រទេសវៀតណាម*

ខ្ញុំមិនដឹងជាត្រូវចាប់ផ្តើមពីកន្លែងណាទៅទេ ក្រោយពេលដែលបានសំរេចចិត្តបញ្ជូនកូនស្រីរបស់ខ្ញុំឲ្យទៅរៀននៅបរទេស។ ភ្នាក់ងារអប់រំនៅបរទេស បានប្រាប់ពីការធ្វើតេស្តរបស់ AEAS ហើយថាវារឿងប្រសើរបំផុតដែលយើងបានធ្វើ។ ការធ្វើតេស្តបានប្រាប់ពីកំរិតឆ្នាំសិក្សាដែលត្រឹមត្រូវ កំរិតភាសាអង់គ្លេសដែលត្រូវរៀនបំប៉នបន្ថែម ហើយបានដាក់ចេញនូវកំរិតសមត្ថភាពរបស់កូនស្រីខ្ញុំទៅនឹងសាលាដែលយើងកំពុងដាក់ពាក្យសុំចូលរៀននោះតែម្តង។ វាគឺជាព័ត៌មានដ៏ល្អបំផុតដែលយើងបានទទួលដើម្បីរៀបចំផែនការថវិកា និងកាលបរិច្ឆេទចាប់ផ្តើមរបស់យើង!”

*អ្នកស្រី Kitty Cheung មកពីទីក្រុងហុងកុង*

## ការវាយតម្លៃរបស់ AEAS រួមមាន៖

## 1 | ជំនាញផ្នែកភាសាអង់គ្លេស

## 2 | លទ្ធភាពបកស្រាយគណិតវិទ្យា

## 3 | លទ្ធភាពទូទៅនៃការបកស្រាយមិនផ្ទាល់មាត់

ការធ្វើតេស្តមានរយៈពេលប្រហែលជា៣ម៉ោង

សិស្សត្រូវដាក់ឲ្យអង្គុយធ្វើតេស្តទៅតាមអាយុរបស់ពួកគេ និងកំរិតឆ្នាំដែលពួកគេដាក់ពាក្យសុំចូលរៀន។ ឧទាហរណ៍ សិស្សម្នាក់បច្ចុប្បន្ននេះរៀនថ្នាក់ទី៩ ហើយកំពុងដាក់ពាក្យសុំចូលរៀនថ្នាក់ទី១០នៅឆ្នាំបន្ទាប់ នឹងត្រូវបានដាក់ឲ្យអង្គុយធ្វើតេស្តភាសាអង់គ្លេសថ្នាក់ទី១០-១២ និងតេស្តគណិតវិទ្យាថ្នាក់ទី១០ ហើយនិងតេស្តពិនិត្យលទ្ធភាពទូទៅ។

ការធ្វើតេស្តជំនាញភាសាអង់គ្លេសរបស់ AEAS មិនផ្តល់លទ្ធផលជាប់ ឬធ្លាក់ទេ។ លទ្ធផលតេស្ត ផ្តល់ព័ត៌មានត្រឹមត្រូវលើលទ្ធភាពរបស់សិស្ស ដើម្បីចាប់យកបរិយាកាសសិក្សាភាសាអង់គ្លេសនៅថ្នាក់មធ្យម។

## ភាសាអង់គ្លេស-ថ្នាក់ទី១០-១២

ការធ្វើតេស្តត្រូវបានបង្កើតយ៉ាងជាក់លាក់ សម្រាប់សិស្សកំពុងចូលរៀនថ្នាក់ទី១០-១២

- **អក្ខរាវិរុទ្ធ**-(២០នាទី) សំណួរមានជំរើសច្រើន ការផ្គុំពាក្យ និងបំពេញចន្លោះ។
- **ការអានដែលឆាប់យល់**-(៣០នាទី) សំណួរមានជំរើសច្រើន ការផ្គុំពាក្យ ការបំពេញចន្លោះ និងការបំពេញដ្យាក្រាម។
- **ជំនាញក្នុងការសរសេរ**-(៣០នាទី) សិស្សសរសេរពាក្យ២០០ អំពីប្រធានបទដែលចាប់អារម្មណ៍ ហើយទាក់ទងទៅនឹងអាយុ និងប្រវត្តិរបស់ពួកគេ។
- **ជំនាញក្នុងការស្តាប់**-(២០នាទី) សំណួរមានជំរើសច្រើន ការផ្គុំពាក្យ ការបំពេញចន្លោះ និងការបំពេញដ្យាក្រាម។
- **ការនិយាយ**-(១០-១៥នាទី) ការធ្វើតេស្តរួមមានកិច្ចការសន្ទនាមួយជួរ។ សិស្សធ្វើការបង្ហាញខ្លីមួយលើប្រធានបទជាក់លាក់ បំពេញកិច្ចការរូបភាព ហើយចាប់ផ្តើមការពិភាក្សា។ ការធ្វើតេស្តនិយាយទាំងអស់ត្រូវបានថតសម្លេងទុក។

## ភាសាអង់គ្លេស-ថ្នាក់ទី៧-៩

បែបបទនៃការធ្វើតេស្ត គឺស្រដៀងគ្នានឹងការធ្វើតេស្តសម្រាប់ថ្នាក់ទី១០-១២។ ការធ្វើតេស្តទាំងអស់ត្រូវបានបង្កើតឡើងយ៉ាងជាក់លាក់សម្រាប់សិស្សចូលរៀនថ្នាក់ទី៧-៩។

- **អក្ខរាវិរុទ្ធ**-(៣០នាទី) សំណួរជាការផ្គុំពាក្យ ពាក្យក្នុងបរិបទ(បំពេញចន្លោះ) និងការប្រកប។
- **ការអានដែលឆាប់យល់**-(៣០នាទី) សំណួរមានជំរើសច្រើន ការផ្គុំពាក្យ ការបំពេញចន្លោះ និងការបំពេញដ្យាក្រាម។

- **ជំនាញក្នុងការសរសេរ**-(៣០នាទី) សិស្សសរសេរពាក្យ២០០ អំពីប្រធានបទដែលចាប់អារម្មណ៍ ហើយទាក់ទងទៅនឹង អាយុ និងប្រវត្តិរបស់ពួកគេ។
- **ជំនាញក្នុងការស្តាប់**-(២០នាទី) សំណួរមានជំរើសច្រើន ការផ្គុំពាក្យ ការបំពេញចន្លោះ និងការបំពេញដ្យាក្រាម។
- **ការនិយាយ**-(១០-១៥នាទី) ការធ្វើតេស្តស្រដៀងគ្នានឹងការធ្វើតេស្តនិយាយសម្រាប់ថ្នាក់ទី១០-១២។ ប្រធានបទត្រូវបានរៀបចំទៅតាមអាយុ និងកំរិតឆ្នាំរបស់សិស្ស។ ការធ្វើតេស្តនិយាយទាំងអស់ត្រូវបានថតសម្លេងទុក។

## ភាសាអង់គ្លេស-ថ្នាក់ទី៤-៦

បែបបទនៃការធ្វើតេស្ត គឺស្រដៀងគ្នានឹងការធ្វើតេស្តសម្រាប់ថ្នាក់ទី៧-៩។ ការធ្វើតេស្តទាំងអស់ត្រូវបានបង្កើតឡើងយ៉ាងជាក់លាក់សម្រាប់សិស្សចូលរៀនថ្នាក់ទី៤-៦។

## លទ្ធភាពបកស្រាយគណិតវិទ្យា

ការធ្វើតេស្តលើលទ្ធភាពបកស្រាយគណិតវិទ្យាមានរយៈពេល៤៥នាទី។ ក្រដាសតេស្តខុសៗគ្នាត្រូវបានគេប្រើដោយយោលទៅតាមកំរិតឆ្នាំដែលសិស្សកំពុងដាក់ពាក្យសុំចូលរៀន។ ការធ្វើតេស្តទាំងអស់ វាយតម្លៃលើលទ្ធភាពបកស្រាយគណិតវិទ្យា ហើយមិនមានមូលដ្ឋានលើកម្មវិធិសិក្សាឡើយ។ សំណួរមានជំរើសច្រើន។

ដើម្បីទទួលបានលទ្ធផលត្រឹមត្រូវ សិស្សមិនត្រូវហ្វឹកហាត់ធ្វើតេស្តបកស្រាយគណិតវិទ្យាឡើយ។

## លទ្ធភាពទូទៅ

ការធ្វើតេស្តលើលទ្ធភាពទូទៅ គឺមិនប្រើភាសារទេ ហើយមានរយៈពេល៣០នាទីដើម្បីបញ្ចប់។ វាគឺជាការធ្វើតេស្តដោយមិនបកស្រាយផ្ទាល់មាត់ យោលទៅតាមសំណួរដែលមានជំរើសច្រើន ដែលផ្តល់ការបង្ហាញមួយនៃកំរិតលទ្ធភាពទូទៅរបស់សិស្ស។ ពិន្ទុសរុប ផ្តល់សន្ទស្សន៍នៃសមត្ថភាពគំនិតប្រាជ្ញា និងភាពឯករាជ្យនៃការសិក្សាលើប្រធានបទជាក់លាក់។ ដើម្បីទទួលបានលទ្ធផលត្រឹមត្រូវ សិស្សមិនត្រូវហ្វឹកហាត់ធ្វើតេស្តបកស្រាយគណិតវិទ្យាឡើយ។

## សម្ភារៈហាត់ធ្វើតេស្ត

សម្ភារៈហាត់ធ្វើតេស្តភាសាអង់គ្លេស អាចរកបានសម្រាប់ការធ្វើតេស្តថ្នាក់ទី៤-៦ ថ្នាក់ទី៧-៩ និងថ្នាក់ទី១០-១២។ សូមយោងទៅ **www.aeas.com.au/practice-test-materials/overview** សម្រាប់ព័ត៌មានបន្ថែមស្តីអំពីរបៀបទិញសម្ភារៈហាត់ធ្វើតេស្ត។

## របៀបចុះឈ្មោះដើម្បីធ្វើតេស្ត

ការធ្វើតេស្តមានជាង២៥ប្រទេសនៅជុំវិញពិភពលោក ដូចជាប្រទេសចិន ហុងកុង ឥណ្ឌូណេស៊ី ជប៉ុន កូរ៉េ ម៉ាឡេស៊ី សាំងកាប៉ូ តៃវ៉ាន់ ថៃ និងវៀតណាម។ ការធ្វើតេស្តក៏មានផ្តល់ផងដែរនៅក្នុងប្រទេសអូស្ត្រាលី។ ការធ្វើតេស្តនេះត្រូវបានរៀបចំយ៉ាងទៀងទាត់ទៅតាមតំរូវការក្នុងទីកន្លែងជាច្រើនដែលពុំបានចុះបញ្ជីក្នុងគេហទំព័ររបស់ AEAS។ សូមទាក់ទងមក AEAS សម្រាប់ព័ត៌មានបន្ថែម។

សូមយោងទៅ **www.aeas.com.au/how-to-register** សម្រាប់ព័ត៌មានស្តីអំពីទីតាំងធ្វើតេស្ត របៀបចុះឈ្មោះ និងតម្លៃធ្វើតេស្ត ហើយនិងដំណើរការបង់ប្រាក់។

## អ្វីដែលត្រូវយកមកជាមួយសម្រាប់ការធ្វើតេស្ត

- រូបថតទំហំលិខិតឆ្លងដែន១សន្លឹក( ជារូបថតថ្មីៗដោយមានសរសេរឈ្មោះសិស្សយ៉ាងច្បាស់នៅខាងក្រោយរូបថត )
- របាយការណ៍សិក្សាច្បាប់ដើម និងច្បាប់ចំលង១ច្បាប់ ( បកប្រែរួច )
- លិខិតឆ្លងដែនច្បាប់ដើម និងច្បាប់ចំលង១ច្បាប់ ឬអត្តសញ្ញាណប័ណ្ណដទៃទៀតដែលមានបិទរូបថត
- ប៊ិចពណ៌ខ្មៅសម្រាប់សរសេរ
- ច្បាប់ចម្លងនៃអ៊ីម៉េលដែលបញ្ជាក់អំពីការធ្វើតេស្ត

ទូរស័ព្ទដៃ និងគ្រឿងអេឡិកត្រូនិក នឹងមិនត្រូវបានអនុញ្ញាតឲ្យយកចូលក្នុងបន្ទប់ធ្វើតេស្តក្នុងពេលណាមួយឡើយ។

ព័ត៌មានស្តីពីបែបបទ និងលក្ខខណ្ឌក្នុងការធ្វើតេស្តអាចរកបាននៅលើគេហទំព័រ **www.aeas.com.au**។ សិស្សទាំងឡាយណាដែលទើបធ្វើតេស្តរួចក្នុងអំឡុងពេល៣ខែនៃកាលបរិច្ឆេទធ្វើតេស្តពីមុន មិនបានអនុញ្ញាតឲ្យចូលអង្គុយធ្វើតេស្ត AEAS ទៀតឡើយ។

# ទម្រង់ការចុះឈ្មោះ




## របាយការណ៍ AEAS

របាយការណ៍ AEAS ផ្តល់នូវ៖

- ពិន្ទុមួយសម្រាប់ការធ្វើតេស្តភាសាអង់គ្លេសបន្ទាប់បន្សំនីមួយៗ និងពិន្ទុជំនាញភាសាអង់គ្លេសទូទៅគិតត្រឹម១០០ពិន្ទុចុះ
- អនុសាសន៍លើកម្មវិធីភាសាអង់គ្លេសខ្លាំងក្លាដែលតម្រូវ ក្នុងរយៈពេលជាច្រើនសប្តាហ៍
- ពិន្ទុដើម និងពិន្ទុស្តង់ដារសម្រាប់ការធ្វើតេស្តបកស្រាយគណិតវិទ្យា និងលទ្ធភាពទូទៅ។
- អនុសាសន៍លើកំរិតថ្នាំត្រូវចូលសិក្សានៅសាលារៀន

## អនុសាសន៍លើវិធីភាសាអង់គ្លេសខ្លាំងក្លា

| កម្រិតពិន្ទុ | | សប្តាហ៍<br>ការចូលរៀនសាលាមធ្យមសិក្សាថ្នាក់ខ្ពស់ ថ្នាក់ទី១០-១២ | សប្តាហ៍<br>ការចូលរៀនសាលាមធ្យមសិក្សាថ្នាក់ទាប ថ្នាក់ទី៧-៩ | សប្តាហ៍<br>ការចូលរៀនសាលាបឋមសិក្សា |
|---|---|---|---|---|
| ០-២៥ | អ្នកទើបចាប់ផ្តើមរៀន | ៤០-៤៨ | ៣០-៤០ | ១២-២០ |
| ២៦-៣៥ | ថ្នាក់បឋម | ៣០-៤០ | ២០-៣០ | ៦-១២ |
| ៣៦-៤៥ | មុនថ្នាក់កណ្តាល | ២០-៣០ | ១២-២០ | ៤-៦ |
| ៤៦-៦០ | ថ្នាក់កណ្តាល | ១២-២០ | ៨-១២ | ០ |
| ៦១-៧០ | ថ្នាក់កណ្តាលជាន់ខ្ពស់ | ៨-១២ | ៤-៨ | ០ |
| ៧១-៨០ | មុនថ្នាក់ខ្ពស់ | ០-៨ | ០ | ០ |
| ៨០+ | ថ្នាក់ខ្ពស់ | ០ | ០ | ០ |






សាលាដែលធ្វើតេស្តលើការដាក់ពាក្យសុំ ពិចារណាលើរយៈពេលនៃកម្មវិធីភាសាអង់គ្លេសខ្លាំងក្លានៅពេលកំណត់កាលបរិច្ឆេទចាប់ផ្តើមរបស់សិស្ស។ ពេលវេលាគ្រប់គ្រាន់គួរត្រូវបានផ្តល់ឲ្យសិស្សដើម្បីបង្កើតជំនាញភាសាអង់គ្លេសចាំបាច់ក្នុងបរិយាកាសសិក្សាភាសាអង់គ្លេស។ សាលារៀនទាំងអស់អាចធ្វើតេស្តសិស្សឡើងវិញនៅពេលចាប់ផ្តើមដើម្បីពិនិត្យមើលប្រសិនបើពួកគេបានត្រៀមខ្លួនរួចរាល់។

របាយការណ៍របស់ AEAS ត្រូវបានសរសេរដោយ AEAS ក្នុងប្រទេសអូស្ត្រាលី។ របាយការណ៍ទាំងនោះត្រូវបានផ្ញើទៅកាន់៖

- គ្រប់សាលាដែលសិក្សដាក់ពាក្យសុំចូលរៀន
- សិស្ស/មាតាបិតា
- ភ្នាក់ងារអប់រំ (ប្រសិនបើមានព័ត៌មានលំអិតនៅក្នុងពាក្យសុំចុះឈ្មោះ)

របាយការណ៍របស់ AEAS នឹង៖

- ជួយមាតាបិតាសិស្ស និងភ្នាក់ងារអប់រំដែលជួយសិស្សទៅរៀននៅបរទេស ឲ្យជ្រើសរើសសាលាដែលត្រូវនឹងតំរូវការព្រមទាំងសមត្ថភាពរបស់សិស្ស។
- ជួយដល់សាលា ឲ្យយល់ពីលទ្ធភាពរបស់សិស្ស និងផ្តល់ការចុះឈ្មោះមួយដ៏សមរម្យ។
- យល់ដឹងពីជំនាញភាសាអង់គ្លេសបច្ចុប្បន្នរបស់សិស្ស។
- កាត់បន្ថយការប្រថុយប្រថានរបស់សិស្សក្នុងការចូលរៀនក្នុងសាលាមធ្យមសិក្សា មុនពេលពួកគេមានជំនាញភាសាអង់គ្លេសចាំបាច់។
- ជួយមាតាបិតាសិស្ស ឲ្យធ្វើផែនការថវិកាសម្រាប់ការសិក្សានៅបរទេស ដែលបូករួមទាំងការចំណាយលើកម្មវិធីបំប៉នបន្ថែមភាសាអង់គ្លេស។

* សិស្សមិនត្រូវទទួលព្រមធ្វើវគ្គត្រៀមសម្រាប់ការធ្វើតេស្តឡើយ ដ្បិតអីការធ្វើបែបនេះអាចនាំឲ្យទទួលបានពិន្ទុមិនត្រឹមត្រូវ។ សិស្សអាចទទួលគុណវិបត្តិការចាញ់ប្រៀប ប្រសិនបើពួកគេចូលសាលារៀនដោយពុំមានជំនាញភាសាអង់គ្លេសល្អគ្រប់គ្រាន់។ សិស្សត្រូវបានណែនាំឲ្យបញ្ចប់វគ្គសិក្សាភាសាអង់គ្លេស ដ្បិតអីនេះគឺវិធីល្អបំផុតដើម្បីកែលម្អជំនាញភាសាអង់គ្លេសរបស់ពួកគេ។

សូមចូលមើលវិបសាយ AEAS – **www.aeas.com.au** សម្រាប់ព័ត៌មានបន្ថែម រួមមាន **សំណួរដែលគេតែងសួរញឹកញាប់ (FAQs)**។



**សេវាវាយតម្លៃការអប់រំនៅប្រទេសអូស្ត្រាលី (AEAS)**
ABN 68 108 370 770

**ការិយាល័យធំ**
Level 1, 383 Clarendon Street, South Melbourne, 3205, Australia

ទូរស័ព្ទ: +61 3 9645 0077
អ៊ីម៉ែល: admin@aeas.com.au
វិបសាយ: www.aeas.com.au

AEAS Australia

ប្រព័ន្ធដាក់ពាក្យសុំចូលរៀនសាលាអូស្ត្រាលី
វិបសាយ: www.aeasschools.aeas.com.au

ការិយាល័យនៅប្រទេសចិន - Beijing
ទូរស័ព្ទ +86 10 8454 9147 / +86 10 8454 9157
អ៊ីម៉ែល: infochina@aeas.com.cn
វិបសាយ: www.aeas.com.cn

AEAS®

30 YEARS OF QUALITY
INTERNATIONAL
STUDENT ASSESSMENTS
KHMER12/17